# គ្រឿងឥស្សរិយយស
# នៃ
# ព្រះរាជាណាចក្រកម្ពុជា



## CAMBODIAN
## DECORATIONS OF HONOR

# សញ្ញារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា



Coat Of Arms Of The Government Of
The Kingdom Of Cambodia

# គ្រឿងឥស្សរិយយស
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

## COMBODIAN
## DECORATIONS OF HONOR

រៀបរៀងដោយ ឌៀន ម៉ៅ

រក្សាសិទ្ធិ

# អារម្ភកថា

សៀវភៅដែលខ្ញុំបាទចងក្រងនេះ គឺនិយាយរៀបរាប់អំពីគ្រឿងឥស្សរិយយស ដែលមានតាំងពីសម័យអាណានិគមនិយមបារាំងរហូតមកដល់សព្វថ្ងៃនេះ ។ គោលបំណងក្នុងការតាក់តែងសៀវភៅនេះ គឺដើម្បីស្រាវជ្រាវ និងរក្សាទុកនូវឯកសារទាំងឡាយ ដែលបានបាត់បង់ក្នុងរបបប្រល័យពូជសាសន៍ ហើយក៏ចង់បង្ហាញឲ្យកូនចៅជំនាន់ក្រោយ ស្វែងយល់អំពីរូបភាពមេដាយ មុខសញ្ញាជូនមេដាយ និងស្នាដៃដែលត្រូវជូនមេដាយ ។

ការចងក្រងសៀវភៅនេះ ក៏ចង់បង្ហាញឲ្យឃើញថា ការដឹកនាំនិងគ្រប់គ្រងប្រទេសក្នុងសម័យកាលនីមួយៗ សុទ្ធតែយកគ្រឿងឥស្សរិយយស នេះសំរាប់ជំរុញនិងលើកទឹកចិត្តចំពោះមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធនិងប្រជាពលរដ្ឋ ដែលបានខិតខំទាំងកម្លាំងកាយចិត្តបំពេញភារកិច្ច ហើយមានស្នាដៃជូនជាតិមាតុភូមិ ។

អត្ថបទនិងរូបភាពនៅក្នុងសៀវភៅនេះ មិនទាន់គ្រប់ជ្រុងជ្រោយទេ ប៉ុន្តែខ្ញុំបាទយល់ថា អាចបានជាគំនិតខ្លះសំរាប់អ្នកស្រាវជ្រាវទាំងឡាយយកទៅពិនិត្យនិងស្វែងយល់ អំពីគ្រឿងឥស្សរិយយស នៃព្រះរាជ-ជាណាចក្រកម្ពុជា ។

សូមគោរពនិងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះឧបទេសដ៏ល្អរបស់ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដល់រូបខ្ញុំបាទក្នុងការបំពេញការងារក៏ដូចជាក្នុងការសរសេរសៀវភៅនេះដោយបានឲ្យឯកឧត្តម **ពេជ្រ ប៊ុនធិន** រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងឯកឧត្តម **ជាង ផេងងួន** អគ្គលេខាធិការរងរាជរដ្ឋាភិបាលជួយពិនិត្យ និងកែសម្រួលក្នុងការចងក្រងសៀវភៅនេះ ។

សង្ឃឹមថានឹងមានការយោគយល់ និងអធ្យាស្រ័យពីសំណាក់លោកអ្នកអានគ្រប់រូប ចំពោះកង្វះខាត និងកំហុសឆ្គងទាំងឡាយដែលមានក្នុងសៀវភៅនេះ។

ខ្ញុំបាទរង់ចាំទទួលការទិតៀនកែលំអដោយក្តីសោមនស្សរីករាយជានិច្ច និងសូមអរគុណ ។

ភ្នំពេញ,ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៨

ឌៀង ម៉ៅ

# ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា

ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នមានផ្ទៃដីទំហំ ១៨១.០៣៥ គីឡូម៉ែត្រក្រឡាស្ថិតនៅប៉ែកនិរតីនៃឧបទ្វីបឥណ្ឌូចិនមានព្រំប្រទល់ប៉ែកខាងលិច និងពាយព្យជាប់នឹងប្រទេសថៃឡង់ដ៏ ខាងជើង និងឦសានជាប់នឹងប្រទេសឡាវ និងបូព៌ាជាប់នឹងប្រទេសវៀតណាម ។ ព្រះរាជាណាចក្រកម្ពុជា ស្ថិតនៅតំបន់ត្រូពិកមានអាកាសធាតុក្តៅហើយសើម មានខ្ពង់រាបព័ទ្ធជុំវិញអាងបឹងទន្លេសាបដែលភ្ជាប់មកទន្លេមេគង្គ ។

ក្នុងសម័យអង្គរពីឆ្នាំ ៨០២ ដល់ឆ្នាំ ១៤៣១ ប្រទេសកម្ពុជាមានការរីកចម្រើនរុងរឿងនិងល្បីល្បាញយ៉ាងខ្លាំង។ ព្រះបាទជ័យវរ្ម័នទី២ដែលមានព្រះខ័នសក្តិសិទ្ធនៅតែជានិមិត្តសញ្ញានៃអំណាចនាពេលបច្ចុប្បន្នបានឡើងសោយរាជ្យនៅឆ្នាំ ៨០២ ។ ក្នុងអំឡុងនៃការគ្រងរាជ្យ ព្រះអង្គបានបង្រួបបង្រួមអាណាចក្រចេនឡាចាស់ដែលមានព្រំប្រទល់ជាប់នឹង ខេត្តយូណានប្រទេសចិន ទឹកដីរបស់ប្រទេសឡាវ និងទឹកដីជាច្រើនរបស់សៀម (បច្ចុប្បន្នហៅថៃឡង់ដ៏) មកជាអាណាចក្ររបស់ព្រះអង្គ ។ ក្នុងអំឡុងសតវត្សទី ១២ ប្រាសាទ **អង្គរវត្ត** ត្រូវបានស្ថាបនាចប់សព្វគ្រប់។ប្រាសាទនេះបានក្លាយជានិមិត្តសញ្ញារបស់ប្រទេសកម្ពុជានិងត្រូវបានអន្តរជាតិទទួលស្គាល់ជាអច្ឆរិយៈពិភពលោក។ ប្រាសាទ **បាយ័ន** និង **អង្គរធំ** ត្រូវបានសាងសង់បន្ថែមនៅក្នុងបរិវេណក្រុងអង្គរក្នុងអំឡុងសតវត្សក្រោយ ។

ព្រះបាទជ័យវរ្ម័នទី៧ ដែលបានសោយរាជ្យពីឆ្នាំ ១១៨១ ដល់ឆ្នាំ ១២១៥ ត្រូវបានចាត់ទុកជាព្រះមហាក្សត្រខ្មែរដ៏ល្បីល្បាញក្នុងប្រវត្តិសាស្ត្រ ហើយក្នុងអំឡុងនៃការគ្រងរាជ្យរបស់ព្រះអង្គអាណាចក្រនេះមានវិសាលភាពធំធេងបំផុត។ ក្រោយពីព្រះអង្គចូលទីវង្គត់ព្រះរាជាណាចក្រកម្ពុជា បានធ្លាក់ចុះទន់ខ្សោយយ៉ាងគំហុកដោយមានសង្គ្រាមប្រយុទ្ធគ្នាជាច្រើនលើក។ ប្រាសាទអង្គរវត្ត បានធ្លាក់ក្នុងកណ្តាប់ដៃរបស់សត្រូវឈ្លានពានសៀមនៅឆ្នាំ ១៣៥៣ ។ ក្រោយពីការឆក់ប្លន់ជ័យភ័ណ្ឌ និងការធ្វើអាជីវកម្ម សត្រូវឈ្លានពានបានដកថយ ហើយបានត្រឡប់មកវិញម្តងទៀត នៅឆ្នាំ ១៤១៦ ។ នៅឆ្នាំ ១៤១៧ ក្សត្រខ្មែរព្រះនាម **ពញាយ៉ាត** ដែលភៀសព្រះកាយចេញពីក្រុងអង្គរ នៅពេលសៀមវាយ ព្រះអង្គបានកេណ្ឌទ័ពរំដោះក្រុងអង្គរមកវិញ។នៅឆ្នាំ ១៤៣១ ដោយឈ្វេងយល់ថាក្រុងអង្គរជិតសៀមពេកពុំមានលទ្ធភាពទប់ទល់ចំពោះការវាយលុករបស់សៀម បានព្រះអង្គក៏បានប្តូររាជធានីមកតាំងនៅ ទួលបាសានស្រីសន្ធរ ខេត្តកំពង់ចាម តែដោយរាជធានីថ្មីនេះលិចទឹកនៅរដូវវស្សា ព្រះអង្គក៏លើករាជធានីពីទួលបាសានមកតាំងនៅចតុមុខភ្នំពេញវិញ ។

ក្រោយ **ព្រះបរមរាជាពញាយ៉ាត** ចូលទីវង្គត់ទៅរាជបុត្ររបស់ព្រះអង្គព្រះនាម **ស្រីសុគន្ធបទ** បានឡើងគ្រងរាជ្យបន្តនៅឆ្នាំ ១៥០៤ ហើយបានប្តូររាជធានីពីភ្នំពេញ មកទួលបាសានវិញ ។ ព្រះបាទ **ស្រីសុគន្ធបទ** បានសម្លាប់ឃុនហ្លួង ព្រះស្តេចកន (ប្អូនប្រុសរបស់ស្នំឯករបស់ព្រះអង្គ) តែមិនបានសម្រេចក៏ត្រូវឃុនហ្លួងព្រះស្តេចកនកេណ្ឌទ័ពច្បាំងតរហូតធ្វើគត់បាននៅបន្ទាយស្ទឹងសែននៅឆ្នាំ ១៥១២ ។ ឃុនហ្លួង ព្រះស្តេចកនបានឡើងគ្រងរាជ្យមានព្រះនាមថា **ព្រះស្រីជេដ្ឋាធិរាជ** នឹងបានកសាងរាជធានីថ្មីមួយ នៅស្រុកត្បូងឃ្មុំ

ខេត្តកំពង់ចាមដែលព្រះអង្គប្រសិទ្ធនាមថាៈ **រាជធានីស្រឡប់ផ្ទួនគីរីជ័យព្រៃនគរ** ។ នៅឆ្នាំ ១៥២៥ ក្រោយពីបានយកជ័យជំនះលើ **ព្រះស្រីជេដ្ឋាធិរាជ** ព្រះបរមរាជ **អង្គចន្ទ** បានលើករាជធានីមកតាំងនៅលង្វែកដោយកសាងជាបន្ទាយមួយធំមានរបងឫស្សីព័ទ្ធជុំវិញរឹងមាំ ។ តែដោយសារការបែកបាក់ផ្ទៃក្នុង បន្ទាយលង្វែកត្រូវបានសៀមវាយយកនៅឆ្នាំ ១៥៩៤។

តាំងពីពេលនោះមក កម្ពុជាស្ថិតក្នុងស្ថានភាពខ្ទេចខ្ទាំដោយសង្គ្រាម ប៉ុន្តែក្នុងរាជវង្សដែលម្ខាងពឹងសៀម ម្ខាងទៀតពឹងយួន ឲ្យមកធ្វើសង្គ្រាមលើទឹកដីកម្ពុជា និងបែងចែកតំបន់គ្រប់គ្រងរៀងៗខ្លួនរហូតដល់រជ្ជកាលហ្លួងហិរិរក្សរាមា **អង្គឌួង** និង **នរោត្តម** ដែលអំពាវនាវសុំការការពារពីបារាំងនិងចុះសន្ធិសញ្ញា អាណាព្យាបាល ឆ្នាំ ១៨៦៣ ទើបចប់ការឈ្លានពាន ពីសៀម និងអណ្ណាម ។

តាមលក្ខខ័ណ្ឌនៃសន្ធិសញ្ញា ឆ្នាំ ១៨៦៣ ប្រទេសបារាំងមានសិទ្ធិគ្រប់គ្រង កិច្ចការបរទេសរបស់កម្ពុជា ហើយទទួលខុសត្រូវការពារព្រះរាជាណាចក្រកម្ពុជា ។ ដើម្បីឲ្យសៀមយល់ព្រម ទទួលយកការការពាររបស់បារាំង ខេត្តចំនួន២នៅភាគខាងលិចប្រទេសកម្ពុជា ត្រូវបានប្រគល់ឲ្យប្រទេសសៀម ។

នៅខែ មេសា ឆ្នាំ ១៨៦៤ ប្រទេសកម្ពុជា ត្រូវបានប្រកាសឲ្យស្ថិតនៅក្រោម អាណាព្យាបាលរបស់ប្រទេសបារាំង នៅឆ្នាំ ១៨៨៤ បារាំងបានបង្ខំហ្លួងនរោត្តមឲ្យឡាយព្រះហស្តលេខាលើសន្ធិសញ្ញា ដាក់កម្ពុជាជាអាណានិគមបារាំងរហូតមក ។ ព្រះបាទសម្តេច នរោត្តម សីហនុ បានទទួលគ្រងរាជ្យជាព្រះមហាក្សត្រ នៅខែ មេសា ឆ្នាំ ១៩៤១ ។ ទោះជាយ៉ាងណាក៏ដោយបារាំងបានតែងតាំងអគ្គទេសាភិបាលម្នាក់ជាអ្នកដឹកនាំផ្នែកការងាររដ្ឋបាល ។

ក្រោមការដឹកនាំរបស់បារាំង រហូតដល់ពេលមានការផ្តួលទ័ពបារាំង ដោយប្រទេសអាល្លឺម៉ង់ នៅខែឧសភា ឆ្នាំ ១៩៤០ មិនដែលមានការប្រយុទ្ធគ្នានៅឥណ្ឌូចិន។ រដ្ឋាភិបាលបារាំងដែលមាន Vichy ជាប្រមុខបានបង្កើតឡើងហើយបន្តគ្រប់គ្រងអាណានិគម។កងទ័ពជប៉ុនបានចូលមកឈ្លានពាន អាណានិគមបារាំងហើយ បានកាន់កាប់បន្ទាយកងទ័ពបារាំង ទាំងអស់នៅឥណ្ឌូចិន។

នៅខែ មករា ឆ្នាំ ១៩៤១ប្រទេសកម្ពុជាត្រូវបានលុកលុយឈ្លានពានដោយកងទ័ពប្រទេសថៃឡង់ដ៏ក្នុងការប៉ះទង្គិចគ្នា ខាងកងទ័ពជើងទឹកកងទ័ពថៃត្រូវបានរុញច្រានដល់កោះចាង ឈូងសមុទ្រសៀមហើយត្រូវបរាជ័យ ។ ខាងជើងគោកគ្មានភាគីណាមួយ ទទួលបានជោគជ័យឡើយ ។ ទីបញ្ចប់ជប៉ុនបានចូលធ្វើអន្តរាគមន៍ហើយបង្ខំរដ្ឋាភិបាល Vichy ឲ្យចុះហត្ថលេខា លើសន្ធិសញ្ញាជាមួយប្រទេសថៃឡង់ដ៏ ។ ខេត្តបាត់ដំបង និងខេត្តសៀមរាប ត្រូវបានប្រគល់ឲ្យប្រទេសកម្ពុជាវិញ នៅឆ្នាំ ១៩៤៦ ។

ជាមួយនឹងការរំដោះរបស់បារាំងនៅឆ្នាំ ១៩៤៤ និងការបញ្ចប់សង្គ្រាមនៅអឺរ៉ុបរដ្ឋាភិបាល Vichy នៅឥណ្ឌូចិន បានរៀបចំផែនការបះបោរប្រឆាំងនឹងទ័ពជប៉ុន ទោះជាយ៉ាងណាក៏ដោយទ័ពជប៉ុនមិនព្រមចុះចាញ់ទេ ហើយនៅ ខែ មីនា ឆ្នាំ ១៩៤៥ រដ្ឋាភិបាលជប៉ុនបានគ្រប់គ្រងឥណ្ឌូចិន ជាផ្លូវការហើយបានចាប់ឃុំខ្លួនកងទ័ពបារាំង ។

នៅប្រទេសកម្ពុជាជប៉ុនបានតែងតាំងលោក **ស៊ឺង ង៉ុកថាញ់** ជានាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសហើយបានប្រកាសឯករាជ្យ នៅថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៤៥។ ឯករាជ្យនេះមានរយៈពេលខ្លី

ពីព្រោះកងទ័ពសម្ព័ន្ធមិត្តបានចូលមករាជធានីភ្នំពេញ នៅខែ កញ្ញា ឆ្នាំ ១៩៤៥ ហើយបានចាប់ខ្លួនលោក **ស៊ឺង ង៉ុកថាញ់** ដែលជាអ្នករួមការងារជាមួយជប៉ុនយកទៅប្រទេសបារាំង ។

ទោះបីសភាពការណ៍មានការវិវត្តន៍យ៉ាងនេះក៏ដោយ ការចរចាជាមួយបារាំង នៅទីក្រុងព្រៃនគរ នាចុងឆ្នាំ ១៩៤៥ ប្រទេសកម្ពុជាត្រូវបានប្រកាសជាព្រះរាជាណាចក្រស្វ័យភាពនៅក្នុងសហភាពបារាំងក្នុងខែ មករា ឆ្នាំ ១៩៤៦ ។ ឯករាជ្យត្រូវបានទទួលពេញលេញ នៅថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ ។

នៅថ្ងៃទី ២ ខែ មីនា ឆ្នាំ ១៩៥៥ សម្តេច **ព្រះនរោត្តម សីហនុ** បានដាក់រាជ្យដើម្បីចូលរួមក្នុងអាជីពជាអ្នកនយោបាយព្រះអង្គបានបង្កើត គណបក្សសង្គមរាស្ត្រនិយម ហើយទទួលបានជ័យជំនះក្នុងការបោះឆ្នោតជាតិនៅខែ កញ្ញា ឆ្នាំ ១៩៥៥ ។ ក្រោមកិច្ចដឹកនាំរបស់ព្រះអង្គ ប្រទេសបានរីកចម្រើនលើគ្រប់វិស័យ ហើយបានក្លាយជាសមាជិករបស់អង្គការសហប្រជាជាតិ ។ នៅថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៥៥ ព្រះបាទ **នរោត្តម សុរាម្រិត** ជាព្រះបិតារបស់សម្តេច **ព្រះនរោត្តម សីហនុ** បានឡើងគ្រងរាជ្យ ។ នៅខែ មេសា ឆ្នាំ ១៩៦០ ព្រះអង្គចូលទីវង្គត់ហើយព្រះបាទ **នរោត្តម សីហនុ** ត្រូវបានប្រកាសជាប្រមុខរដ្ឋ។ ទោះបីពុំមានព្រះមហាក្សត្រពិតប្រាកដដើម្បីឡើងគ្រងរាជ្យក៏ដោយក៏ព្រះមហាក្សត្រិយានី **ស៊ីសុវត្ថិ កុសុមៈ** ជាព្រះមាតារបស់ព្រះបាទ **នរោត្តម សីហនុ** បានក្លាយទៅជានិមិត្តរូបនៃព្រះមហាក្សត្រ ។

នៅចុងឆ្នាំ ១៩៦០ សង្គ្រាមនៅប្រទេសវៀតណាមបានគំរាមកំហែងសន្តិភាព និងសេចក្តីសុខសាន្តរបស់កម្ពុជា ។ នៅឆ្នាំ ១៩៦៩ ផ្លូវផ្គត់ផ្គង់ដ៏សំខាន់របស់វៀតណាមខាងជើងភ្ជាប់ខាងត្បូងគឺទីក្រុងហូជីមិញត្រូវឆ្លងកាត់តំបន់បូព៌ានៃប្រទេសកម្ពុជា ហើយសហរដ្ឋអាមេរិកចាប់ផ្តើមប្រតិបត្តិការទំលាក់គ្រាប់បែកបេ៥២នៅខែមីនាឆ្នាំ១៩៧០ក្រោមសម្ពាធពីសហរដ្ឋអាមេរិកឧត្តមសេនីយ៍ **លន់ ណុល** ជាអគ្គបញ្ជាការកងទ័ពកម្ពុជាបានរៀបចំរដ្ឋប្រហារដើម្បីទំលាក់សម្តេច **ព្រះនរោត្តម សីហនុ** ដែលកំពុងបំពេញព្រះរាជទស្សនកិច្ចនៅប្រទេសបារាំង ។ រដ្ឋប្រហារនេះកើតឡើងរយៈពេលមួយខែ ក្រោយសហរដ្ឋអាមេរិក និងវៀតណាមខាងត្បូងបានរួមគ្នា បើកប្រតិបត្តិការ នៅភាគបូព៌ាប្រទេសកម្ពុជា ប្រឆាំងនឹងចលនាបះបោរ របស់វៀតណាមខាងជើង។ ទោះជាយ៉ាងណាក៏ដោយប្រតិបត្តិការនេះមិនបានទទួលជោគជ័យទាំងស្រុងទេហើយកងទ័ពវៀតណាមខាងជើងត្រូវបានរុញច្រានចូលជ្រៅក្នុងទឹកដីកម្ពុជា ។

នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧០ របបសាធារណរដ្ឋខ្មែរត្រូវបានបង្កើតឡើងដោយមាន **លន់ ណុល** ជាប្រធានាធិបតី ។

ពេលនោះប្រទេសកម្ពុជា មានជាប់ពាក់ព័ន្ធយ៉ាងខ្លាំងនៅក្នុងជម្លោះវៀតណាម ហើយរយៈពេលជាង ៥ ឆ្នាំក្រោយមកពួកបះបោរកុម្មុយនីស្តដែលហៅថាខ្មែរក្រហម បានក្លាយទៅជាកងប្រដាប់អាវុធជាតិគ្រប់គ្រងទឹកដី។ កងទ័ពខ្មែរក្រហមបានកាន់កាប់ទឹកដីមួយផ្នែកធំនៅតំបន់ជនបទហើយនៅឆ្នាំ ១៩៧៥ បានចូលមកដល់ទីក្រុងភ្នំពេញ។ ទីក្រុងភ្នំពេញបានធ្លាក់មកក្នុងកណ្តាប់ដៃ របស់ខ្មែរក្រហម នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ក្រោយ **លន់ ណុល** បានចាកចេញពីប្រទេសរយៈពេលមួយសប្តាហ៍ប៉ុណ្ណោះ ។

ដោយនឿយណាយនឹងសង្គ្រាមរយៈពេល ៥ ឆ្នាំ កន្លងមកប្រជាជននៅទីក្រុងភ្នំពេញ បាននាំគ្នាអបអរសាទរ និងស្វាគមន៍ពួកខ្មែរក្រហមដែលជាអ្នករំដោះ។ ប៉ុន្តែក្នុងរយៈពេលតែប៉ុន្មានម៉ោងក្រោយកងកំលាំងប្រដាប់អាវុធខ្មែរក្រហម បានបង្ខំឱ្យប្រជាជនទាំងអស់នៅទីក្រុងចាកចេញទៅជនបទ ។ បន្ទាប់

ពីការស៊ូទ្រាំ នឹងសង្គ្រាមរយពេល ៥ ឆ្នាំ ប្រជាជនកម្ពុជាត្រូវធ្លាក់ក្នុងស្ថានភាពនៃការបង្ខិតបង្ខំឱ្យធ្វើការបាក់កម្លាំងអត់ឃ្លានការធ្វើទារុណកម្ម និងប្រល័យពូជសាសន៍អស់រយៈជិត ៤ ឆ្នាំ ។ ក្រោមអំណាចរបស់ខ្មែរក្រហម ប្រជាជនជាង ១ លាន នាក់បានស្លាប់ដោយលំបាកវេទនាជាទីបំផុត ។

នៅឆ្នាំ ១៩៧៨ ខ្មែរក្រហមបានចាប់ផ្តើមបោសសំអាតផ្ទៃក្នុងរបស់ខ្លួន ។ កងទ័ពនិងជនស៊ីវិលជាច្រើនត្រូវបានចោទប្រកាន់ជាជនក្បត់ជាតិ ហើយបញ្ជូនមកដាក់គុកទួលស្លែង នៅទីក្រុងភ្នំពេញនិងកន្លែងផ្សេងៗទៀតទូទាំងប្រទេសដែលគ្មាននរណាម្នាក់អាចរស់រានមានជីវិត ។ ដោយមើលឃើញអំពើប្រល័យពូជសាសន៍ អ្នកស្នេហាជាតិមួយចំនួនបានរត់ចូលព្រៃ និងទៅប្រទេសវៀតណាមហើយក៏បានបង្កបង្កើតទ័ពឡើង ។ នៅចុងឆ្នាំ ១៩៧៨ កងទ័ពនេះដោយមានជំនួយពីសម្ព័ន្ធមិត្តវៀតណាម បានចាប់ផ្តើមប្រយុទ្ធនៅប្រទេសកម្ពុជា ហើយទីក្រុងភ្នំពេញត្រូវបានរំដោះនៅថ្ងៃទី ៧ មករា ឆ្នាំ ១៩៧៩ ។ សាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវបានបង្កើតឡើងដែលមានលោក **ហេង សំរិន** ជាមេដឹកនាំ ។ ខ្មែរក្រហមមិនទាន់បរាជ័យទាំងស្រុងទេនៅឆ្នាំ១៩៧៩ ហើយបានបន្តប្រយុទ្ធជាសង្គ្រាមទ័ពព្រៃជាមួយរដ្ឋាភិបាលថ្មីអស់រយៈពេលជាងមួយទសវត្ស ។

នៅឆ្នាំ១៩៨៩ ដោយយល់ឃើញថាការបង្រួបបង្រួម ប្រទេសមិនអាចដោយស្រាយ បានតាមមធ្យោបាយយោធាកងទ័ពវៀតណាមត្រូវត្រលប់ទៅប្រទេសវិញ ។ នៅថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៨៩ ឈ្មោះប្រទេសត្រូវបានប្តូរមកជារដ្ឋកម្ពុជា ហើយតាមរយៈការចរចាសន្តិភាព ជាហូរហែត្រូវបានស្នើឡើងដោយភាគីជម្លោះទាំងអស់ ។ ការចរចាទាំងនេះបាន ឈានទៅដល់ការព្រមព្រៀង ដោយស្ម័គ្រចិត្តស្តីពីបទឈប់បាញ់ដែលចុះហត្ថលេខានៅថ្ងៃ ០១ ខែ ឧសភា ឆ្នាំ ១៩៩១ រវាងរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកក្នុងរយៈពេលដ៏ខ្លី ក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា ត្រូវបានបង្កើតឡើងដោយសម្តេចព្រះ **នរោត្តម សីហនុ** ជាប្រធានហើយក្រុមប្រឹក្សានេះ បានបង្កើតរដ្ឋាភិបាលបណ្តោះអាសន្នរហូតដល់ការរៀបចំបោះឆ្នោត ដោយអង្គការសហប្រជាជាតិ ។

ការបោះឆ្នោតជាសកលត្រូវបានធ្វើឡើងនៅខែ ឧសភា ឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើងដោយមានព្រះអង្គម្ចាស់ **នរោត្តម រណឫទ្ធិ** ជានាយករដ្ឋមន្ត្រីទី ១ សម្តេច **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីទី ២ ។

រដ្ឋធម្មនុញ្ញថ្មីត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ព្រះបាទសម្តេច **នរោត្តម សីហនុ** បានឡើងគ្រងរាជ្យ ជាថ្មីជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។ នៅថ្ងៃ ២៩ ខែ តុលា ឆ្នាំ ២០០៤ ព្រះករុណាព្រះបាទសម្តេចព្រះ **បរមនាថ នរោត្តម សីហមុនី** បានឡើងគ្រងរាជ្យបន្តរហូតដល់បច្ចុប្បន្ន បន្ទាប់ពីព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានសុំចូលនិវត្តន៍ ។

# គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

## CAMBODIAN DECORATIONS OF HONOR

*គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលនៅក្នុងអាណត្តិទី១ តាមព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ដើម្បីទទួលស្គាល់នូវគុណបំណាច់និងស្នាដៃមន្ត្រីរាជការស៊ីវិលយោធិន នគរបាលជាតិប្រជាពលរដ្ឋខ្មែរនិងសហគមន៍អន្តរជាតិ ។*

**តាមព្រះរាជក្រឹត្យនេះមានមេដាយចំនួន១៩ មុខដែលចែងជាបួនប្រភេទ គឺ ៖**

**ប្រភេទទី១** : *ប្រភេទមាតុប្រទេសមានមេដាយ* **ជាតូបការ** *មេដាយ* **ព្រះរាជាណាចក្រកម្ពុជា** *និងមេដាយ* **ឯករាជ្យជាតិ** ។

**ប្រភេទទី២** : *ប្រភេទ* **រាជបល្ល័ង្ក** *មានមេដាយ* **រាជសម្បត្តិ** *មេដាយ* **រជ្ជកាល** *និង* **មេដាយអនុស្សរា**

**ប្រភេទទី៣** : *ប្រភេទការពារជាតិ មានមេដាយ* **សេនាជ័យសិទ្ធ** *និង មេដាយ* **ការពារជាតិ**

**ប្រភេទទី៤** : *ប្រភេទចម្រុះមានមេដាយ* **សហមេត្រី** *មេដាយ* **សុវត្ថារា** *មេដាយ* **មុនីសារាភ័ណ្ឌ** *មេដាយ* **ការងារ** *មេដាយ* **ស្ថាបនាជាតិ** *មេដាយ* **ខេមរាកីឡាឫទ្ធិ** *និង មេដាយ* **ស្ត្រីវឌ្ឍនា** ។

*មេដាយថ្នាក់ខ្ពស់បំផុត របស់ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្នគឺ មេដាយ* **ជាតូបការ** *មានតែមួយថ្នាក់គត់។ មេដាយពីរទៀតគឺ មេដាយ* **ឯករាជ្យជាតិ** *និងមេដាយ* **សេនាជ័យសិទ្ធ** *ក៏មានតែមួយថ្នាក់ដែរ ។*

*មេដាយព្រះរាជាណាចក្រកម្ពុជា មានប្រាំថ្នាក់ដូចពីមុន ប៉ុន្តែមានការកែប្រែបន្តិចបន្តួច ដូចជាមកុដរាជ្យបារាំងបូរាណ ត្រូវបានផ្លាស់ប្តូរមកជាមកុដរាជ្យខ្មែរ ។តួមេដាយព្រះរាជណាចក្រកម្ពុជាថ្នាក់* **មហាសេនា** *ពីមុនធ្វើអំពីលោហៈធាតុបានផ្លាស់ប្តូរពីប្រាក់មកស្រោបទឹកមាសវិញ រីឯខ្សែក្រណាត់ត្រូវបានរក្សាទុកដូចដើម ។*

*តាមព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ មេដាយ* **សហមេត្រី** *មេដាយ* **សុវត្ថារា** *និងមេដាយ* **មុនីសារាភ័ណ្ឌ** *មានតែ៣ថ្នាក់ទេ ប៉ុន្តែអនុលោមតាមឯកសារដែលមាន កន្លងមកមេដាយទាំងនេះត្រូវបន្ថែម២ថ្នាក់ទៀត ។ ចំពោះក្រណាត់ភ្ជាប់មេដាយត្រូវបានរក្សាទុកតាមទំរង់ដើមដូចមុន ។*

# មេដាយជាតូបការ

## *MEDAL OF NATIONAL MERIT*

មេដាយនេះត្រូវបានបង្កើត នៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៤៨ ដោយមានឈ្មោះថា ៖ មេដាយគុណូបការជាតិ ប៉ុន្តែក្រោយមកត្រូវដូរឈ្មោះមកជាមេដាយ **ជាតូបការ** វិញតាមព្រះរាជក្រឹត្យ លេខ២៧ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៦៣ ។ មេដាយជាតូបការត្រូវបានបង្កើតឡើងវិញ តាមរាជក្រឹត្យលេខ ជស/រកត/១០៩៥/០៦ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៩៩៥ ។ មេដាយនេះគឺជាមេដាយខ្ពស់បំផុត របស់ព្រះរាជាណាចក្រកម្ពុជា ហើយមានតែមួយថ្នាក់គត់សំរាប់បំពាក់ជូនអ្នកដែលមានគុណូបការ ដ៏ឧត្តុង្គឧត្តមបំផុតក្នុងបុព្វហេតុឯករាជ្យ សាមគ្គីភាព ប្រជាធិបតេយ្យ និងសន្តិភាពជូនជាតិមាតុភូមិ។

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានទំរង់ជាផ្កាយប្រាំបីជ្រុងមានកាំរស្មី ៤៨ មានវិជ្ជមាត្រប្រវែង ៧៥ ម.ម ហើយមានមកុដមួយនៅពីលើ ។ នៅកណ្ដាលមានរង្វង់មូលដែលមានទង់ជាតិជានិមិត្តរូប ហើយនៅជុំវិញរង្វង់មូលមានសរសេរអក្សរថា មេដាយជាតូបការ ។ ផ្នែកខាងខ្នងនៃតួមេដាយមានភាពភ្លឺរលោង ។ តួមេដាយនេះភ្ជាប់ជាមួយខ្សែធ្វើអំពីលោហធាតុពណ៌មាស ចំនួន៣០ កាំ សម្រាប់ពាក់ដូចបន្តោងខ្សែក ។



មេដាយ ជាតូបការ

**Medal Of National Merit**

# មេដាយព្រះរាជាណាចក្រកម្ពុជា

## ROYAL ORDER OF CAMBODIA

មេដាយ **ព្រះរាជាណាចក្រកម្ពុជា** ត្រូវបានបង្កើតឡើងនៅថ្ងៃ ទី ៨ ខែ កុម្ភៈ ឆ្នាំ ១៨៦៤ ដោយព្រះបាទសម្តេច **នរោត្តម** ដើម្បីប្រគល់ជូនមន្ត្រីរាជការស៊ីវិល និងបុគ្គលិក កងទ័ព ដែលបម្រើការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៨៩៦ មេដាយនេះត្រូវប្រែក្លាយ ជាមេដាយអាណានិគមបារាំងតាមផ្លូវការដែលគ្រប់គ្រងនៅទីក្រុងប៉ារីស ។ តាមក្រឹត្យចុះ ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ១៨៩៩ ខ្សែបូសម្រាប់មេដាយដែលមានការអនុញ្ញាតពីអាជ្ញាធរបារាំង មានពណ៌ស នឹងពណ៌ទឹកក្រូចនៅផ្នែកគែម ។ ឆ្នាំ១៩៤៨ ក្នុងរជ្ជកាលរបស់ព្រះបាទសម្តេច **នរោត្តម សីហនុ** ការគ្រប់គ្រងមេដាយត្រូវបានប្រគល់ឱ្យកម្ពុជាវិញ ។

បន្ទាប់ពីការបោះឆ្នោត ឆ្នាំ១៩៩៣ ដែលឧបត្ថម្ភដោយ អង្គការសហប្រជាជាតិ ព្រះបាទសម្តេច **នរោត្តម សីហនុ** បានឡើងគ្រងរាជ្យសាជាថ្មី មេដាយនេះត្រូវបានបង្កើតឡើងតាម ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ៥ ខែ តុលា ឆ្នាំ ១៩៩៥ ។

សញ្ញាសំគាល់នៃមេដាយ **ព្រះរាជាណាចក្រកម្ពុជា** ដែលបានបង្កើតឡើងវិញមានការកែប្រែបន្តិចបន្តួចពីទម្រង់ដើមរបស់វា ភាពខុសគ្នាជាសំខាន់ គឺការរៀបចំប្រដាប់ផ្តក់មកុដ ដោយមកុដតាមរបៀបបារាំងមានប្រើប្រាស់តាំងពីឆ្នាំ ១៨៦៤ ហើយត្រូវបានផ្លាស់ជំនួសដោយមកុដរាជខ្មែរវិញ។

មេដាយ **ព្រះរាជាណាចក្រកម្ពុជា** មានទម្រង់ទ្រាយជារូបផ្កាយ ៨ ជ្រុង ផ្សំដោយកាំរស្មី ចំនួន ២៨ ជាគ្រឿងសំគាល់។ នៅកណ្តាលមានរង្វង់ រាងពងក្រពើដែលមានពណ៌ក្រហមព័ទ្ធជុំវិញ។ នៅផ្ទៃខាងក្នុងពងក្រពើនេះមានក្បាច់ភ្ញីភ្លើងពណ៌ស្វាយ នៅខាងលើមានមកុដមួយ និងមានព្រះខ័នពណ៌មាសមួយ ហើយនៅពីក្រោមព្រះខ័នមានជើងពានពណ៌មាសចំនួនពីរត្រួតលើគ្នា។

**មេដាយព្រះរាជាណាចក្រកម្ពុជាមាន ប្រាំថ្នាក់ គឺ ៖**

**១ – មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់ មហាសេរីវឌ្ឍន៍**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានវិជ្ឈមាត្រប្រវែង ៥៥ ម.ម មានដាំត្បូងពណ៌ស នៅខាងចុងនៃផ្កាយទាំង ៨ ។ មេដាយនេះត្រូវដាក់ភ្ជាប់ជាមួយសំពត់រុយបង់ធំពណ៌ ក្រហម ឆ្នូតពណ៌បៃតង សងខាងដែលមានទទឹងប្រវែង ១១០ ម.ម ។ នៅចុងសំពត់នេះមានភ្ជាប់មេដាយមួយគ្រឿងថ្នាក់ធិបឌិន្ទដាំត្បូង។

**២ - មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់ មហាសេនា**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានវិជ្ឈមាត្រប្រវែង ៥៥ ម.ម ពុំមានដាំត្បូងនៅចុងនៃផ្កាយទាំង ៨ ដូចមហាសេរីវឌ្ឍន៍ទេ ។ មេដាយនេះត្រូវពាក់ភ្ជាប់ជាមួយសំពត់រុយបង់ធំ និងនៅចុងសំពត់នេះមានភ្ជាប់មេដាយថ្នាក់ធិបឌិន្ទមួយគ្រឿង ដូចមេដាយថ្នាក់មហាសេរីវឌ្ឍន៍ដែរ ប៉ុន្តែគ្មានដាំត្បូងទេ។

**៣ - មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់ ធិបឌិន្ទ**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានវិជ្ឈមាត្រប្រវែង ៧៥ ម.មមានមកុដមួយនៅពីលើភ្ជាប់ទៅនឹងកំណាត់សំពត់ដែលមានទទឹងប្រវែង ៣៧ ម.ម ។

**៤ - មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់ សេនា**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានវិជ្ឈមាត្រប្រវែង ៦៥ ម.ម មានមកុដមួយនៅពីលើភ្ជាប់នឹងកំណាត់សំពត់ពណ៌ក្រហម និងពណ៌បៃតងដែលមានទទឹងប្រវែង ៣៧ ម.ម ហើយដែលមានផ្កាកុលាបពណ៌ក្រហមនិងពណ៌បៃតងភ្ជាប់នឹងខ្សែបូរ ។

**៥ - មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់ អស្សឫទ្ធិ**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានវិជ្ឈមាត្រប្រវែង ៥៤ ម.ម មានមកុមួយនៅពីលើភ្ជាប់នឹងកំណាត់សំពត់ពណ៌ក្រហម និងពណ៌បៃតង ដែលមានទទឹងប្រវែង ៣៧ ម.ម ។





មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់ សេរីវឌ្ឍន៍

**Royal Order Of Cambodia Grand Cross**





មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់ មហាសេនា
**Royal Order Of Cambodia Grand Officer**



មេដាយព្រះរាជាណាចក្រកម្ពុជា
ថ្នាក់ធិបឌិន្ទ
**Royal Order Of Cambodia**
**Commander**



មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់សេនា
**Royal Order Of Cambodia Officer**



មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់អស្សឫទ្ធិ
**Royal Order Of Cambodia Chevalier**

# មេដាយព្រះរាជាណាចក្រកម្ពុជា
# ដែលបានប្រើប្រាស់ក្នុងអំឡុងឆ្នាំ ១៩៤៨ - ១៩៧០



មេដាយព្រះរាជាណាចក្រ កម្ពុជា
ថ្នាក់ ធិបឌិន្ទ
ផលិតនៅប្រទេសបារាំង







មេដាយព្រះរាជាណាចក្រ
កម្ពុជាថ្នាក់ សេនា
ផលិតនៅប្រ ទេសបារាំង

មេដាយព្រះរាជាណាចក្រ
កម្ពុជាថ្នាក់ សេនា
ផលិតនៅប្រ ទេសកម្ពុជា

មេដាយព្រះរាជាណាចក្រ កម្ពុជាថ្នាក់ អស្សឫទ្ធិ
ផលិតនៅប្រ ទេសកម្ពុជា

# មេដាយព្រះរាជាណាចក្រកម្ពុជា
# ដែលប្រើប្រាស់នៅក្នុងរបបអាណានិគមនិយមបារាំង



មេដាយព្រះរាជាណាចក្រកម្ពុជា
ថ្នាក់ មហាសេរីវឌ្ឍន៍
ផលិតនៅប្រទេសបារាំង



មេដាយព្រះរាជាណាចក្រ កម្ពុជា
ថ្នាក់ សេនា
ផលិតនៅប្រទេសកម្ពុជា



មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់ និបទិន្ទ
ផលិតនៅប្រទេសបារាំង



មេដាយព្រះរាជាណាចក្រកម្ពុជាថ្នាក់ អស្សឫទ្ធិ
ផលិតនៅប្រទេសបារាំង

# មេដាយឯករាជជាតិ

## *NATIONAL INDEPENDENCE MEDAL*

មេដាយ ***ឯករាជ្យជាតិ*** ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ ២៧ រ.វ. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៦៣ ហើយត្រូវបានបង្កើតឡើងវិញតាមព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ។ មេដាយនេះមានតែមួយថ្នាក់ប៉ុណ្ណោះសម្រាប់ប្រគល់ជូនអ្នក ដែលមានបណ្ដាស័ក្តិ បានជួយបម្រើប្រទេសជាតិ មានស្នាដៃក្នុងបុព្វហេតុឯករាជជាតិសាមគ្គីភាព លទ្ធិប្រជាធិបតេយ្យ និងសន្តិភាព ។ អ្នកទទួលមេដាយឯករាជជាតិ ត្រូវបានជ្រើសរើសដោយគណៈរដ្ឋមន្ត្រី ហើយការប្រគល់មេដាយនេះត្រូវមានវត្តមានពីព្រះមហាក្សត្រ ឬអ្នកតំណាងដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ ។

តួសំគាល់មេដាយនេះធ្វើ អំពីលោហៈធាតុពណ៌មាស មានវិជ្ជមាត្រប្រវែង ៥៥ ម.ម ។ ផ្នែកខាងមុខមានកម្រងផ្កាវាងពងក្រពើមានសន្លឹកដើមឃីចោនៅខាងក្នុង ដែលមានរូបវិមានឯករាជ្យ នៅពីលើមានកាំរស្មីតូចធំចំនួន ១៦ កាំ ។ ផ្នែកខាងខ្នងនៃមេដាយមានភាពភ្លឺរលោង ។ វិមានឯករាជ្យដែលស្ថិត នៅចំផ្លូវខ្វែងនៃមហាវិថី **ព្រះនរោត្តម** និងវុក្ខវិថី **ព្រះសីហនុ** ត្រូវបានស្ថាបនានៅឆ្នាំ ១៩៥៨ ដើម្បីរំឭកដល់ថ្ងៃឯករាជជាតិ របស់ប្រទេសកម្ពុជាពីអាណានិគមបារាំងក្នុងឆ្នាំ ១៩៥៣ ។ វិមានឯករាជ្យនេះក៏សម្រាប់រំឭកវិញ្ញាណក្ខន្ធរបស់អ្នកដែលបានពលីជីវិតក្នុងអំឡុងពេលសង្គ្រាមផងដែរ។តួមេដាយព្យួរពីខ្សែបូពណ៌ក្រហមមានទទឹងប្រវែង ៣៧ ម.ម ដោយមានឆ្នូតពណ៌ខៀវក្រាស់ និងឆ្នូតពណ៌ខៀវស្តើង ២ អមនៅគែមសងខាង ហើយមានផ្កាកុលាបនៅចំកណ្តាល។



មេដាយឯករាជជាតិ

**National Independence Medal**

# មេដាយសេនាជ័យសិទ្ធ

## SENA JAYASEDDH MEDAL

មេដាយ **សេនាជ័យសិទ្ធ** ត្រូវបានបង្កើតឡើង តាមព្រះរាជប្រកាស លេខ ១១០ ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ១៩២៨ ដោយភាគីកម្ពុជានិងប្រកាសលេខ ៣៧៩៨ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩២៨ ដោយភាគីបារាំង ។ មេដាយនេះត្រូវបានប្រគល់ជូនពលទាហាន នាយទាហាននៃកងទ័ពជាតិ ឬនាយនគរបាលជាតិ ដែលមានស្នាដៃល្អ នៅក្នុងសង្គ្រាមឬក្នុងការងារការពារព្រំដែនជាតិ និងសន្តិសុខជាតិ ហើយក៏អាចប្រគល់ជូនទាហាន និងជនស៊ីវិល ដែលបានបម្រើការងារទាក់ទងនឹងការការពារជាតិ ។ មេដាយនេះក៏អាចប្រគល់ជូននាយទាហានជាន់ខ្ពស់ សម្រាប់ការងារផ្សេងៗទៀតផងដែរ ។ មេដាយសេនាជ័យសិទ្ធ មានតម្លៃស្មើគ្នានឹងមេដាយបារាំងដែរ ។

មេដាយសេនាជ័យសិទ្ធត្រូវបានបង្កើតឡើងវិញតាមព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ។ តាមបទបញ្ញត្តិបច្ចុប្បន្នអ្នកទទួលត្រូវមាន មេដាយថ្នាក់ការពារជាតិ ចំនួន ៣ ជាមុនសិន ។

**តួសំគាល់** មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានវិជ្ជមាត្រប្រវែង ៣៩ ម.ម មានរូបកងចក្រតំណាងព្រះពុទ្ធសាសនា ហ៊ុំព័ទ្ធដោយពានទ្រព្រះខ័ន ។ កងចក្រនេះឆ្លាក់ក្បាច់ជាសត្វគ្រុឌ នៅក្នុងលោហៈធាតុពណ៌មាស ដោយមានស្លាបរបស់វាត្រដាង នៅពីលើនិងកន្ទុយនៅពីក្រោមក្រញាំជើងទាំងពីរជាប់កន្ទុយនាគក្បាល៧ ។

ក្នុងរបបសាធារណរដ្ឋខ្មែរ មេដាយនេះត្រូវបានផ្លាស់ប្តូររូបភាពបន្តិចបន្តួច ទាំងតួមេដាយទាំងខ្សែបូរ ។ នៅលើតួមេដាយមាន មកុដភ្ជាប់ជាមួយខ្សែបូ ពណ៌ខៀវមានទទឹងប្រវែង ៣៧ ម.ម ដោយមានឆ្នូតពណ៌ក្រហម និងលឿងនៅគែមសងខាង។ ខ្សែបូកណ្តាលមានពណ៌ខៀវហើយមានផ្កាយពណ៌លឿងនៅចំកណ្តាលខ្សែបូ ។



មេដាយជ័យសិទ្ធ

**Sena Jayaseddh Medal**



មេដាយសេនា ជ័យសិទ្ធ(សាធារណរដ្ឋខ្មែរ ១៩៧០--១៩៧៥)

**Sena Jayaseddh Medal (Khmer Republic 1970-1975)**

# មេដាយការពារជាតិ

## *NATIONAL DEFENSE MEDAL*

មេដាយ **ការពារជាតិ** ត្រូវបានបង្កើតឡើងនៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៤៨ ដែលមានតម្លៃស្មើនឹងមេដាយបារាំង France Croix De Guerre ។ មេដាយនេះត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ ជស/រកត/១០៥៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៥៩ សំរាប់ប្រគល់ជូនពលទាហាន នាយទាហាននៃកងទ័ពជាតិឬនាយនគរបាលជាតិដែលមានស្នាដៃល្អនៅក្នុងសង្គ្រាម ឬក្នុងការងារការពារព្រំដែនជាតិ និងសន្តិសុខជាតិ។

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុ មានរាងមូលមានរូបហនុមានក្នុងសំលៀកបំពាក់ជាខ្មែរ មានកាន់ព្រះខ័ននៅដៃខាងឆ្វេងដែលមានវិជ្ជមាត្រប្រវែង ៣៥ ម.ម ។

មេដាយនេះមាន៣ថ្នាក់គឺ មេដាយមាសការពារជាតិ ប្រាក់ការពារជាតិ និងសំរឹទ្ធការពារជាតិ ។ មេដាយមាស ប្រាក់ និងសំរឹទ្ធ ត្រូវបានប្រគល់ជូនដោយយោងតាមកម្រិតស្នាដៃ ហើយមេដាយប្រាក់ និង សំរឹទ្ធអាចប្រគល់ជូនក្នុងពេលដំណាលគ្នាបាន។ មេដាយដែលត្រូវប្រគល់ជូនបុគ្គលម្នាក់ថ្នាក់ឧត្តមសេនីយ៍ មានចំនួនអតិបរិមា ៦ (មេដាយមាស ២ , ប្រាក់ ២, និងមេដាយសំរឹទ្ធ ២) ។

នៅលើតួមេដាយពីខ្សែបូពណ៌ក្រហម មានទទឹងប្រវែង ៣៧ ម.ម មានឆ្នូតពណ៌ខៀវបួន ដោយមានរូបផ្កាយមាស ប្រាក់ និង សំរឹទ្ធ តាមថ្នាក់មេដាយនៅចំកណ្តាលខ្សែបូ ។

នៅឆ្នាំ ១៩៧០ សម័យសាធារណរដ្ឋខ្មែររូបមកុដត្រូវប្តូរទៅជាផ្កា មាន៩ស្រទាប់ដោយមានស្លឹកតូចៗនៃស្រទាប់នៅពីលើ និងកាំរស្មីមួយគូរាងកោងនៅពីក្រោម ហើយប្រវែងនៃព្រះខ័នត្រូវបានកាត់បន្ថយមកនៅត្រឹម ២៨ ម.ម ។



មេដាយមាសការពារជាតិ
National Defense Medal Gold



មេដាយប្រាក់ការពារជាតិ
National Defense Medal Silver



មេដាយសំរឹទ្ធការពារជាតិ
National Defense Medal Bronze



មេដាយការពារជាតិ
ផលិតនៅប្រទេសបារាំង
(១៩៤៨_១៩៧០)



មេដាយការពារជាតិ
សម័យសាធារណរដ្ឋខ្មែរ
ផលិតនៅកម្ពុជា
(១៩៧០_១៩៧៥)



មេដាយការពារជាតិ
សម័យសាធារណរដ្ឋខ្មែរ
ផលិតនៅសហរដ្ឋអាមេរិក
(១៩៧០_១៩៧៥)

# មេដាយព្រះមហាក្សត្រីយានី.ស.ម.កុសុមៈ

## THE ORDER OF HER MAJESTY THE QUEEN PREAH KOSSOMAK NEARIREATH

មេដាយព្រះមហាក្សត្រីយានី ស.ម.កុសុមៈ ត្រូវបានបង្កើតឡើងដោយ **ព្រះមហាក្សត្រីយានីកុសុមៈ** មាន ៥ ថ្នាក់ នៅថ្ងៃ ទី ១ ខែ តុលា ឆ្នាំ ១៩៦២ ដើម្បីប្រគល់ជូនអ្នកដែលមានស្នាដៃក្នុងការបំពេញសេវាព្រះរាជបល្ល័ង្ក ។ មេដាយនេះត្រូវបានបង្កើតឡើងវិញនៅដើមឆ្នាំ ២០០១ ។

តួសំគាល់មេដាយនេះធ្វើអំពីលោហៈពណ៌មាស មានកាំរស្មីចំនួន ៣២ ដែលបានរចនាគ្រប់អង្កាំទឹកមាសតូចៗជាច្រើន។ នៅផ្ចិតកណ្ដាលមានរូបព្រះមហាក្សត្រីយានីកុសុមៈ បែរព្រះភ័ក្ត្រទៅខាងឆ្វេង ហ៊ុំព័ទ្ធជារង្វង់ដោយអក្សរទឹកមាសថា មេដាយព្រះមហាក្សត្រីយានី ស.ម.កុសុមៈ ។ តួមេដាយមានមកុដភ្ជាប់ជាមួយខ្សែបូ មានពណ៌ក្រហម រួមទាំងឆ្នូតពណ៌បៃតងតូច នៅក្បែរគែមនីមួយៗ ។

**មេដាយសម្ដេចព្រះមហាក្សត្រីយានី ស.ម កុសុមៈ មាន ៥ ថ្នាក់ គឺ ៖**

**១- មេដាយ សម្ដេចព្រះមហាក្សត្រីយានី ស.ម កុសុមៈ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុមាស មានវិជ្ឈមាត្រប្រវែង ៩៥ ម.ម មានភ្ជាប់ដោយខ្សែសំពត់ពណ៌ក្រហមរួមទាំងឆ្នូតពណ៌បៃតង តូចនៅក្បែរគែមនីមួយៗខ្សែសំពត់នេះ មានទទឹងប្រវែង ១១០ ម.ម ដោយនៅខាងចុងមានភ្ជាប់មេដាយមួយគ្រឿងថ្នាក់ ធិបឌិន្ទ ។

**២- មេដាយ សម្ដេចព្រះមហាក្សត្រីយានី ស.ម កុសុមៈ ថ្នាក់ មហាសេនា :**

តួសំគាល់មេដាយនេះ ធ្វើអំពីលោហៈធាតុមាសមានវិជ្ឈមាត្រប្រវែង ៨៥ម.ម មានភ្ជាប់ដោយខ្សែសំពត់ពណ៌ក្រហមរួមទាំងឆ្នូតពណ៌បៃតងតូចនៅក្បែរគែមនីមួយៗ ខ្សែសំពត់នេះមានទទឹងប្រវែង ១១០ ម.ម ដោយនៅខាងចុងមានភ្ជាប់មេដាយមួយគ្រឿងថ្នាក់ ធិបឌិន្ទ ដូចមេដាយមហាសេរីវឌ្ឍន៍ដែរ។

**៣- មេដាយ សម្ដេចព្រះមហាក្សត្រីយានី ស.ម កុសុមៈ ថ្នាក់ ធិបឌិន្ទ :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុមាស មានវិជ្ឈមាត្រប្រវែង ៥៨ ម.ម មានមកុដមួយនៅពីលើភ្ជាប់ទៅនឹងកំណាត់សំពត់ដែលមានទទឹងប្រវែង ៣៧ ម.ម ។

**៤- មេដាយ សម្ដេចព្រះមហាក្សត្រីយានី ស.ម កុសុមៈ ថ្នាក់ សេនា :**

តួសំគាល់មេដាយនេះ ធ្វើអំពីលោហៈធាតុមាស មានវិជ្ឈមាត្រប្រវែង ៤៨ម.ម មានមកុដមួយនៅពីលើភ្ជាប់ទៅនឹងកំណាត់សំពត់ដែលមានទទឹងប្រវែង ៣៧ ម.ម ដោយមានបុប្ផាកុលាបនៅចំកណ្ដាល។

**៥- មេដាយ សម្ដេចព្រះមហាក្សត្រីយានី ស.ម កុសុមៈ ថ្នាក់ អស្សឫទ្ធិ :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុមាស មានវិជ្ឈមាត្រប្រវែង ៤៨ ម.ម មានមកុដមួយនៅពីលើភ្ជាប់ទៅនឹងកំណាត់សំពត់ដែលមានទទឹងប្រវែង ៣៧ ម.ម ។





មេដាយសម្តេចព្រះមហាក្សត្រិយានី ស.ម.កុសុមៈថ្នាក់ មហាសេរីវឌ្ឍន៍

**Order Of H.M The Queen Preah Kossomak Neareath Grand Cross**





មេដាយសម្តេចព្រះមហាក្សត្រិយានី ស .ម.កុសុមៈថ្នាក់ មហាសេនា

**Order Of H.M The Queen Preah Kossomak Neariraeth Grand Officer**



មេដាយ សម្តេចព្រះ មហាក្សត្រិយានី

ស.ម កុសុមៈ ថ្នាក់ ធិបឌិន្ទ

**Order Of H.M The Queen Preah Kossomak**

**Nearieath Commander**





មេដាយ សម្តេចព្រះ មហាក្សត្រិយានី

ស.ម កុសុមៈ ថ្នាក់ សេនា

**Order Of H.M The Queen Preah Kossomak**

**Nearireath Officer**

មេដាយ សម្តេចព្រះ មហាក្សត្រិយានី

ស. ម កុសុមៈ ថ្នាក់ អស្សឫទ្ធិ

**Order Of H.M The Queen Preah Kossomak**

**Nearireath Chevalier**



មេដាយសម្តេចព្រះមហាក្សត្រីយានី ស .ម កុសុមៈ ប្រើមុនឆ្នាំ ១៩៧០

# មេដាយសហមេត្រី

## ROYAL ORDER OF SAHAMETREI

មេដាយសហមេត្រី ត្រូវបានបង្កើតឡើងជាបីថ្នាក់ នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៤៨ ហើយត្រូវបានបង្កើតឡើងដល់ ៥ ថ្នាក់ នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ១៩៥៦ ។ មេដាយនេះត្រូវបានបង្កើតឡើងវិញតាមព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ មានតែបីថ្នាក់ទេ ប៉ុន្តែការប្រើប្រាស់ជាក់ស្តែងសព្វថ្ងៃនេះមានបន្ថែមពីរថ្នាក់ទៀតគឺថ្នាក់មហាសេនា និងថ្នាក់មហាសេរីវឌ្ឍន៍។ មេដាយនេះគឺជាមេដាយការទូតដំបូងដែលបានប្រគល់ជូនឯកអគ្គរដ្ឋទូតរាជទូតឬតំណាងប្រទេសជាមិត្តដែលបានបំពេញភារកិច្ចដើម្បីផលប្រយោជន៍ប្រទេសទាំងពីរ ។ តួមេដាយមានផ្កាយចំនួន៤ជ្រុង ដោយមានកាំរស្មីចំនួន ៥ នៅលើកម្រងផ្កាដែលមានស្លឹកពណ៌បៃតង ។ នៅចំកណ្តាលមានព្រះខ័នធ្វើដោយជើងពានធ្វើអំពីលោហធាតុស្រោប ទឹកមាសលើផ្ទៃពណ៌បៃតង ដែលមានត្របកផ្កា ១៦ ស្រទាប់ ។ ផ្នែកខាងក្នុងនៃតួមេដាយមានភាពភ្លឺរលោង ។

**មេដាយសហមេត្រី មានប្រាំថ្នាក់ គឺ ៖**

**១- មេដាយសហមេត្រីថ្នាក់ មហាសេរីវឌ្ឍន៍ :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាសមានវិជ្ជមាត្រប្រវែង៩០ម.មភ្ជាប់ដោយសំពត់រុយបង់ពណ៌ខៀវ លឿងនិងក្រហម ។ មេដាយនេះត្រូវបានភ្ជាប់ជាមួយសំពត់រុយបង់ដែលមានទទឹងប្រវែង ១១០ ម.ម នៅចុងសំពត់នេះមានភ្ជាប់មេដាយមួយគ្រឿងថ្នាក់ ធិបឌិន្ទ ។

**២- មេដាយសហមេត្រីថ្នាក់ មហាសេនា :**

តួសំគាល់មេដាយនេះ ធ្វើអំពីលោហៈធាតុពណ៌មាស មានវិជ្ជមាត្រប្រវែង ៨០ ម.ម ភ្ជាប់ដោយសំពត់រុយបង់ពណ៌ខៀវ លឿង និងក្រហម ។ មេដាយនេះត្រូវបានភ្ជាប់ជាមួយខ្សែសំពត់ ដែលមានទទឹងប្រវែង ១១០ ម.ម ។ នៅចុងសំពត់នេះ មានភ្ជាប់មេដាយមួយគ្រឿងថ្នាក់ ធិបឌិន្ទ ។

**៣- មេដាយសហមេត្រីថ្នាក់ ធិបឌិន្ទ :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាសរាងមូល មានវិជ្ជមាត្រប្រវែង ៥៧ ម.ម មានមកុដ មួយនៅពីលើភ្ជាប់ទៅនឹងកំណាត់សំពត់ពណ៌ខៀវ លឿង និងក្រហមដែលមានទទឹងប្រវែង ៣៧ ម.ម ។

**៤- មេដាយសហមេត្រីថ្នាក់ សេនា :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស រាងមូលមានវិជ្ជមាត្រប្រវែង ៤១ ម.ម មានមកុដ មួយនៅពីលើភ្ជាប់ទៅនឹងកំណាត់សំពត់ពណ៌ខៀវលឿងនិងក្រហមដែលមានទទឹងប្រវែង៣៧ ម.ម ដោយមានបុប្ផាកុលាបនៅចំកណ្តាល ។

**៥- មេដាយសហមេត្រីថ្នាក់ អស្សឫទ្ធិ :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាងរាងមូលមានវិជ្ជមាត្រប្រវែង៤១ម.ម មានមកុដ មួយនៅពីលើ ភ្ជាប់ទៅនឹងកំណាត់សំពត់ពណ៌ខៀវ លឿង និងក្រហម ដែលមានទទឹងប្រវែង ៣៧ ម.ម ។





មេដាយសហាមេត្រីថ្នាក់ មហាសេរីវឌ្ឍន៍

**Royal Order Of Sahametrei Grand Cross**





មេដាយសហមេត្រីថ្នាក់ មហាសេនា

**Royal Order Of Sahametrei Grand Officer**



មេដាយ សហមេត្រីថ្នាក់ ធិបឌិន្ទ

**Royal Order Of Sahametrei**

**Commander**



មេដាយ សហមេត្រីថ្នាក់ សេនា

**Royal Order Of Sahametrei Officer**



មេដាយ សហមេត្រីថ្នាក់ អស្សឫទ្ធិ

**Royal Order Of Sahametrei Chevalier**







មេដាយសហាមេត្រី ប្រើប្រាស់មុនឆ្នាំ ១៩៧០ ផលិតនៅប្រទេសបារាំង

# មេដាយសុវត្ថារា

## ROYAL ORDER OF SOWATHARA

មេដាយ **សុវត្ថារា** ត្រូវបានបង្កើតឡើងនៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩២៣ តាមព្រះរាជក្រមហើយ បានធ្វើសច្ចានុម័ត តាមព្រះរាជក្រឹត្យចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ១៩២៣ ។ មេដាយនេះ ត្រូវបានផ្តួចផ្តើមដោយក្រសួងកសិកម្មតាមអនុសាសន៍ របស់អគ្គសេនាប្រមុខសាធារណរដ្ឋបារាំង។

មេដាយសុវត្ថារានេះពីមុនចែកចេញជា៣ថ្នាក់ នៅថ្ងៃទី២៣ ខែ សីហា ឆ្នាំ ១៩៥៦ ត្រូវបានបង្កើនឡើងដល់៥ថ្នាក់ហើយត្រូវបានបង្កើតជាថ្មីតាមព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ មានតែបីថ្នាក់ទេ ប៉ុន្តែការប្រើប្រាស់ជាក់ស្តែងសព្វថ្ងៃនេះ មានបន្ថែមពីរថ្នាក់ទៀតគឺ ថ្នាក់មហាសេរីវឌ្ឍន៍ និងថ្នាក់មហាសេនា សំរាប់ប្រគល់ជូនអ្នកដែលមានស្នាដៃ ឬបានជួយជ្រោមជ្រែងក្នុងវិស័យកសិកម្ម ឬសេដ្ឋកិច្ច ។

តួមេដាយមានផ្កាយ៤ជ្រុង ដែលជ្រុងនីមួយៗមានកាំរស្មីចំនួន ៥ ។នៅចន្លោះកាំរស្មីមានស្លឹកតូចៗចំនួន៤ ដែលជាតំណាងឲ្យកួរស្រូវ,ស្លឹកត្នោត,ពោត,និងកប្បាស ។នៅផ្នែកកណ្តាលមានរូបអង្គរវត្តលើផ្ទៃពណ៌បៃតង។ នៅពីលើតួមេដាយមានរូបនាងគង្ហីងព្រះធរណីច្បូតសក់វែង ក្នុងសំលៀកបំពាក់ជាខ្មែរ ។ ផ្នែកខាងខ្នងនៃតួមេដាយ មានភាពភ្លឺរលោង ។

**មេដាយសុវត្ថារាមាន ប្រាំថ្នាក់ គឺ ៖**

**១- មេដាយសុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាសមានវិជ្ជមាត្រប្រវែង ៧៥ ម.ម មានភ្ជាប់ដោយសំពត់រុយហង់ពណ៌បៃតងមានទទឹង ១១០ ម.ម ហើយនៅចុងសំពត់នេះមានភ្ជាប់មេដាយមួយគ្រឿងថ្នាក់ ធិបឌិន្ទ ។

**២- មេដាយសុវត្ថារាថ្នាក់ មហាសេនា :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានវិជ្ជមាត្រប្រវែង ៧០ ម.ម មានភ្ជាប់ដោយសំពត់រុយហង់ពណ៌បៃតង ទំហំទទឹងដូចគ្នានឹងថ្នាក់ មហាសេរីវឌ្ឍន៍ដែរ ហើយនៅចុងសំពត់នេះមានភ្ជាប់មេដាយមួយគ្រឿងថ្នាក់ ធិបឌិន្ទ។

**៣- មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ :**

តួសំគាល់មេដាយនេះ ធ្វើអំពីលោហៈធាតុពណ៌មាស មានវិជ្ជមាត្រប្រវែង ៥៧ ម.ម មានរូបនាងគង្ហីងព្រះធរណីភ្ជាប់ដោយខ្សែសំពត់ញួរពណ៌បៃតង ដែលមានទទឹងប្រវែង ៣៧ ម.ម ។

**៤- មេដាយសុវត្ថារាថ្នាក់ សេនា :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានវិជ្ជមាត្រប្រវែង ៤០ ម.ម មានរូបនាងគង្ហីងព្រះធរណីភ្ជាប់ទៅនឹងខ្សែសំពត់ញួរពណ៌បៃតងមានទទឹងប្រវែង ៣៧ ម.ម ដោយមានបុប្ផាកុលាបនៅចំកណ្តាល។

**៥-មេដាយសុវត្ថារាថ្នាក់ អស្សឫទ្ធិ :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានវិជ្ជមាត្រប្រវែង ៤០ ម.ម មានរូបនាងគង្ហីងព្រះធរណីភ្ជាប់ទៅនឹងខ្សែសំពត់ញួរពណ៌បៃតង ដែលមានទទឹងប្រវែង ៣៧ ម.ម ។





មេដាយសុវត្ថាភថ្នាក់ មហាសេរីវឌ្ឍន៍

**Royal Order Of Sowathara Grand Cross**





មេដាយសុវត្ថារាថ្នាក់ មហាសេនា
**Royal Order Of Sowathara Grand Officer**



មេដាយសុវត្ថាភថ្នាក់ ធិបឌិន្ទ

Royal Order Of Sowathara Commander



មេដាយសុវត្ថាភថ្នាក់ សេនា

Royal Order Of Sowathara Officer



មេដាយសុវត្ថាភថ្នាក់ អស្សឫទ្ធិ

Royal Order Of Sowathara Chevalier



មេដាយសុវត្ថារា ប្រើប្រាស់មុនឆ្នាំ ១៩៧០

# មេដាយមុនីសារាភ័ណ្ឌ

## *ROYAL ORDER OF MONISARAPHON*

មេដាយ **មុនីសារាភ័ណ្ឌ** ត្រូវបានបង្កើតឡើងថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩០៥ មានតែមួយថ្នាក់គត់សម្រាប់ប្រគល់ជូនអ្នកដែលមានជំនាញផ្នែកប្រវត្តិសាស្ត្រ អក្សរសាស្ត្រ និងវិទ្យាសាស្ត្រ ។ មេដាយនេះត្រូវបានកំណត់ជូនជនជាតិកម្ពុជា និងជនជាតិឥណ្ឌូចិនរបស់បារាំងចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩០៥ ។ មេដាយមុនីសារាភ័ណ្ឌត្រូវបានបង្កើតរហូតដល់៣ថ្នាក់ នៅឆ្នាំ ១៩៤៨ និងដល់៥ថ្នាក់ នៅឆ្នាំ ១៩៦១ ។មេដាយនេះ ត្រូវបានបង្កើតឡើងវិញតាមព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ មានតែបីថ្នាក់ទេប៉ុន្តែការប្រើប្រាស់ជាក់ស្តែងសព្វថ្ងៃនេះមានបន្ថែមពីរថ្នាក់ទៀតគឺ ថ្នាក់មហាសេរីវឌ្ឍន៍ និងថ្នាក់មហាសេនា សម្រាប់ប្រគល់ជូនអ្នកដែលមានស្នាដៃក្នុងវិស័យអប់រំ អក្សរសាស្ត្រ វិទ្យាសាស្ត្រ វិចិត្រសិល្បៈ សង្គមកិច្ច ឬវិស័យផ្សេងទៀត។

មេដាយ **មុនីសារាភ័ណ្ឌ** ធ្វើអំពីលោហៈធាតុពណ៌មាសរាងមូលទ្រវែង ដូចរាងពងក្រពើ ដែលមានមែកឈើពីរទងជាសំខាន់ មែកមួយខាងស្តាំសុទ្ធតែស្លឹកទាំងអស់ មែកមួយខាងឆ្វេងមានផ្លែពីរ ខាងក្រោមលើផ្លែនេះមានស្លឹកមួយរួចមានផ្លែមួយនិងស្លឹកពីរទៀត ហើយមានផ្លែនិងស្លឹកពីរខាងក្រៅ ។ នៅខាងក្នុងមានផ្លែមួយស្លឹកពីរ និងមានផ្លែមួយពីក្រោមទៅលើ ហើយខាងក្នុងមានមែកពីរទ្រជើងពាន ដែលមានដាក់គម្ពីមេដាយនេះភ្ជាប់ដោយសំពត់រុយបង់ពណ៌លឿង ។

**មេដាយមុនីសារាភ័ណ្ឌ មានប្រាំថ្នាក់ គឺ ៖**

**១-មេដាយមុនីសារាភ័ណ្ឌថ្នាក់ មហាសេរីវឌ្ឍន៍ :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានដាំត្បូងពណ៌សត្រង់ផ្លែចំនួន ៦ មានបណ្តោយប្រវែង ៨០ម.ម ទទឹងប្រវែង ៧០ ម.ម មានភ្ជាប់ជាមួយសំពត់រុយបង់ពណ៌លឿងមានទទឹងប្រវែង ១១០ ម.ម ហើយនៅចុងសំពត់នេះមានភ្ជាប់មេដាយមួយគ្រឿងថ្នាក់ ធិបឌិន្ទ ។

**២-មេដាយមុនីសារាភ័ណ្ឌថ្នាក់ មហាសេនា :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានបណ្តោយប្រវែង៧៥ ម.ម ទទឹងប្រវែង៦០ ម.ម ភ្ជាប់ជាមួយសំពត់រុយបង់ពណ៌លឿង មានលក្ខណៈដូចគ្នានឹងមេដាយថ្នាក់ មហាសេរីវឌ្ឍន៍ដែរ តែពុំមានត្បូងពណ៌សទេ ហើយនៅចុងសំពត់នេះមានភ្ជាប់មេដាយមួយគ្រឿងថ្នាក់ ធិបឌិន្ទ ។

**៣-មេដាយមុនីសារាភ័ណ្ឌថ្នាក់ ធិបឌិន្ទ :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានបណ្តោយប្រវែង៦០ ម.ម ទទឹងប្រវែង ៥០ ម.ម ភ្ជាប់ទៅនឹងសំពត់ឮ្សពណ៌លឿងដែលមានទទឹងប្រវែង ៣៧ ម.ម ។

**៤-មេដាយមុនីសារាភ័ណ្ឌថ្នាក់ សេនា :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានបណ្តោយប្រវែង ៤០ ម.ម ទទឹងប្រវែង ៣៥ ម.ម ភ្ជាប់ទៅនឹងសំពត់ខ្សែបូពណ៌លឿងដែលមានទទឹងប្រវែង ៣៧ ម.ម ដោយមានផ្កាកុលាបនៅចំកណ្តាល ។

**៥-មេដាយមុនីសារាភ័ណ្ឌថ្នាក់ អស្សឫទ្ធិ :**

តួសំគាល់មេដាយនេះធ្វើអំពីលោហៈធាតុពណ៌មាស មានបណ្តោយប្រវែង ៤០ ម.ម ទទឹងប្រវែង ៣៥ ម.ម ភ្ជាប់ទៅនឹងសំពត់ខ្សែបូពណ៌លឿងដែលមានទទឹងប្រវែង ៣៧ ម.ម ។





មេដាយមុនីសារាភ័ណ្ឌថ្នាក់ មហាសេរីវឌ្ឍន៍

**Royal Order Of Monisaraphon Grand Crose**





មេដាយមុនីសារាភ័ណ្ឌថ្នាក់ មហាសេនា

**Royal Order Of Monisaraphon Grand Officer**



មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ

**Royal Order Of Monisaraphon, Commander**





មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

**Royal Order Of Monisaraphon**

**Officer**

មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ

**Royal Order Of Monisaraphon**

**Chevalier**